ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តរតនគិរី

សាលាដំបូងខេត្តរតនគិរី
សំណុំរឿងរដ្ឋប្បវេណី
លេខ៥៦/១៤.០៩.១៤
សាលក្រមលេខ ០១(ខ)
ចុះថ្ងៃទី១៧.០៥.១៣

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ លើសំណុំរឿងលេខ៥៦ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោ[redacted] ចៅក្រមសាលាដំបូងខេត្តរតនគិរី

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

សហដើមចោទ ៖

១/ឈ្មោះ [redacted] ដាត ភេទប្រុស អាយុ៤៩ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិជ័យជំនះ សង្កាត់ឡាបាន់សៀក ក្រុងបានលុង ខេត្តរតនគិរី ប្រពន្ធឈ្មោះ [redacted] សំ មានកូន៣ នាក់ ។

២/ឈ្មោះ [redacted] ហ្សាក៏ ភេទប្រុស អាយុ៤១ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

៣/ឈ្មោះ [redacted] រ៉ែនី ភេទប្រុស អាយុ៣៣ឆ្នាំ ល់នៅឋានសព្វថ្ងៃភូមិ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

៤/ឈ្មោះ [redacted] ទូរី ភេទប្រុស អាយុ២៥ឆ្នាំ លំនៅឋានសព្វថ្ងៃភូមិ១ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី នៅលីវ ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទទាំង៤រូប ។

ចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ ហៅ ជុ ភេទស្រី អាយុ៥៦ឆ្នាំ លំនៅឋានសព្វថ្ងៃនៅភូមិ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្តីឈ្មោះ [redacted] ឡេះ (ស) មានកូន៤ នាក់ ។

កម្មវត្ថុបណ្តឹង ដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ បែងចែកមរតករបស់សពឪពុកឈ្មោះ [redacted] ឡេះ នូវដីទំហំ២៧មគុណ៦៨ម ដែលមានសំណង់ផ្ទះ និងសំណង់បន្ទប់ជួលចំនួន២៣បន្ទប់ ស្ថិតនៅភូមិ៧មករា (អតីតភូមិ៣) សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

### អង្គហេតុ និងចំណុចវិវាទ

១/ ការអះអាងរបស់ភាគី

សហដើមចោទ ៖

៤៣៤



Scanned with CamScanner

១/ឈ្មោះ [redacted] ដាត បានថ្លែងការណ៍ថា រូបខ្លួននិងប្អូនចំនួន៣នាក់បានឯកភាពគ្នាដាក់ពាក្យចូលមក តុលាការសុំឲ្យបង្គាប់មកចុងចម្លើយឈ្មោះ [redacted] ម៉ាស់ បែងចែកមរតករបស់សពឪពុកឈ្មោះ [redacted] ឡេះ នូវដីទំហំ២៧ មគុណ៦៨ម ដែលមានសំណង់ផ្ទះ និងសំណង់បន្ទប់ជួលចំនួន២៣បន្ទប់ ឋិតនភូមិទៅភូមិ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ចែកមកកូនទាំង៤នាក់ ពីព្រោះ ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ែទី ឈ្មោះ [redacted] នូរី និងរូបខ្លួនត្រូវជាកូនបង្កើតរបស់សពឈ្មោះ [redacted] ឡេះ ដែលត្រូវទទួលមត៌កខ្លះរបស់ឪពុក ។ កូនៗទាំងអស់នេះ បានរស់នៅបែកពីឪពុកក្នុងពេលដែលមានប្រពន្ធរៀងៗខ្លួនហើយឪពុកក៏មិនទាន់បានចែកទ្រព្យសម្បត្តិមកឲ្យកូនៗ ទាំង៤នាក់នៅឡើយ ។ ចំពោះឪពុករបស់ខ្លួនមានប្រពន្ធ២ដងគឺប្រពន្ធលើកទី១មានកូន៤នាក់ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ែទី ឈ្មោះ [redacted] នូរី និងរូបខ្លួន ។ ក្រោយមកគាត់បានលែងលះពីប្រពន្ធទី១ គាត់បានយកប្រពន្ធមួយទៀតគឺឈ្មោះ ទី ម៉ាស់ គាត់កូន៣នាក់បន្ថែមគឺឈ្មោះ [redacted] រូសាក់ ឈ្មោះ [redacted] ឧសភា និងឈ្មោះ [redacted] ធារី ។ ប៉ុន្តែប្រពន្ធក្រោយនេះគាត់កូនដើមមួយគឺឈ្មោះ [redacted] សេងហុង ។ សព្វថ្ងៃនេះឈ្មោះ [redacted] សេងហុង ឈ្មោះ [redacted] រូសាក់ ឈ្មោះ [redacted] ឧសភា និងឈ្មោះ [redacted] ធារី កំពុងរស់នៅជាមួយឈ្មោះ [redacted] ម៉ាស់ ។ ក្នុងរយៈពេលដែលឪពុករបស់ពួកខ្លួនរស់នៅជាមួយប្រពន្ធឈ្មោះ [redacted] ម៉ាស់ ពីដំបូងពួកគាត់ប្រកបមុខរបរលក់សាច់គោ និងលក់អ្វីផ្សេងៗទៀត បន្ទាប់មកទៀតឪពុករបស់ខ្លួនទទួលបានមុខរបរបន្ថែមគឺបានកាន់កាប់គ្រប់គ្រងកន្លែងសត្វឃាតគោ ។ ក្នុងពេលនោះឈ្មោះ [redacted] ហ្សាគី និងរូបខ្លួន បានស៊ីឈ្នួលកាប់សត្វគោឲ្យពួកគាត់ ។ សព្វថ្ងៃនេះក្រោយពីឪពុករបស់ពួកខ្លួនទទួលមរណភាព ពួកខ្លួនបានដឹងថាទ្រព្យសម្បត្តិរបស់គាត់មានដីទំហំ២៧មគុណ៦៨ម ដែលមានសំណង់ផ្ទះ និងសំណង់បន្ទប់ជួលចំនួន២៣បន្ទប់ ឋិតនភូមិទៅភូមិ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ដែលកំពុងកាន់កាប់ដោយប្រពន្ធឈ្មោះ [redacted] ម៉ាស់ ។ ដីនោះទាំងរូបខ្លួន និងទាំងប្អូនៗមិនដឹងថាមានប័ណ្ណកម្មសិទ្ធិ ឬមិនមានក៏ពុំដឹងដែរ ។ ដីទំហំ១៧ម៉ែត្រគុណ២២ម៉ែត្រ ជាដីរបស់កុងស៊ីកាប់គោ បានប្រគល់មកឲ្យខ្លួន ក្នុងពេលខ្លួនមានមុខរបរកាប់គោក្នុងកុងស៊ីនេះ គឺឪពុកម្ដាយមិនបានចែកឲ្យទេ ។ ដីទំហំ១៥ម៉ែត្រគុណ២៥ម៉ែត្រជាដីដែលគណកម្មការផ្សារបានលុងបានប្រគល់មកឲ្យខ្លួន ជាថ្នូរនឹងដីរបស់ខ្លួនក្នុងផ្សារនេះ គឺឪពុកម្ដាយមិនបានចែកឲ្យទេ ។ ខ្លួនទាមទារចំណែកដីមរតករបស់ឪពុកពួកខ្លួនទាំង៤នាក់ ។

២/ឈ្មោះ [redacted] ហ្សាគី បានថ្លែងការណ៍ថាខ្លួនសុំទាមទារឲ្យចុងចម្លើយចែកមត៌កមកឲ្យពួកខ្លួនទាំង៤នាក់ ដូចដែលបងទាមទារនោះដែរ ។ ដីនិងសំណង់ផ្ទះដែលជាទ្រព្យសម្បត្តិរបស់ឪពុកខ្លួន ក្រោយពីគាត់ទទួលមរណភាពទៅចុងចម្លើយកាន់កាប់ដោយមិនធ្វើការបែងចែកមកឲ្យកូនៗទេ ទោះបីមានគ្នាផ្សះផ្សាតាមប្រពៃណី របស់ឥស្លាមក៏ចុងចម្លើយមិនព្រមធ្វើតាមប្រពៃណីទាំងចាស់ទុំដែរ ។ ដីទំហំ១៧ម៉ែត្រគុណ២២ម៉ែត្រ ជាដីរបស់កុងស៊ីកាប់គោបានប្រគល់មកឲ្យខ្លួនក្នុងពេលខ្លួនមានមុខរបរកាប់គោក្នុងកុងស៊ីនេះ ក្រោយមកខ្លួនទទួលដំណឹងថាដីនេះជាដីផ្លូវ ខ្លួនក៏ចាកចេញពីដី ដោយទៅទិញដីកន្លែងថ្មីរស់នៅ និងទុកដីនោះឲ្យប្អូឈ្មោះ [redacted] សុផាត រស់នៅ បន្ទាប់មកប្អូឈ្មោះ [redacted] សុផាត ក៏ចេញពីដីនេះ ពេលនោះឪពុកបានយកដីនោះមកលក់ឲ្យឈ្មោះ ទ្រុស យ៉ាមីន ។ ដោយឡែកតូបក្នុងផ្សារវិញគឺខ្លួនបានទិញពីគណកម្មការផ្សារក្នុងតម្លៃ២៥០០ដុល្លារ ។ និយាយទៅឪពុក ម្ដាយ មិនទាន់បានចែកទ្រព្យសម្បត្តិមកឲ្យខ្លួននៅឡើយទេ តាំងឪពុកនៅរស់ រហូតដល់គាត់ទទួលមរណភាព ។

៣/ឈ្មោះ [redacted] រ៉ែទី បានថ្លែងការណ៍ថា ខ្លួនទាមទារឲ្យចុងចម្លើយបែងចែកដី ផ្ទះបងប្អូនរួមអាត្មាតាំងដើម

ដែរ ។ ក្នុងនាមខ្ញុំជាកូនៗត្រូវតែទទួលបានចំណែកកេរមរតករបស់សពឪពុកដែលបន្សល់ទុកក្រោយពីគាត់ទទួលមរណភាពទៅ។ ខ្ញុំបានរស់នៅជាមួយឪពុកជាប់រហូត ហើយគាត់ក៏បានរៀបចំផ្សំផ្គុំប្រពន្ធឲ្យមកខ្ញុំដែរ ។ ចំពោះទ្រព្យសម្បត្តិរបស់ឪពុក គឺចុងចម្លើយមិនព្រមបែងចែកមកឲ្យកូនទេ ។

៤/ឈ្មោះ [redacted] ទូរី អវត្តមាន

លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទ បានថ្លែងការណ៍ថា កូនក្តីរបស់ខ្ញុំនៅតែស្នើសុំតុលាការធ្វើការបែងចែកដីទៅតាមការទាមទារដូចក្នុងពាក្យបណ្តឹងរបស់កូនក្តីខ្ញុំ ។ មូលហេតុការទាមទារនេះកូនក្តីរបស់ខ្ញុំបានសំអាងថាដីនិងសំណង់ផ្ទះនេះជាទ្រព្យសម្បត្តិរបស់សពឪពុករបស់ពួកគាត់ ដែលភាគីចុងចម្លើយកំពុងកាន់កាប់គ្រប់គ្រង ។ ក្រោយពីឪពុកពួកគាត់ទទួលមរណភាពទៅគួរណាស់តែចុងចម្លើយត្រូវធ្វើការបែងចែងដីនិងសំណង់ផ្ទះនោះមកឲ្យកូនបែរជាកាន់កាប់តែម្នាក់ឯងទៅវិញ ។ ខ្ញុំជាមេធាវីតំណាងដោយអាណត្តិឲ្យសហដើមចោទ មានសំណូមពរសុំឲ្យតុលាការសម្រេចចែកទ្រព្យសម្បត្តិទៅតាមច្បាប់ ។

ចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ ហៅ ជុ បានថ្លែងការណ៍ថា ខ្ញុំបានរៀបការជាមួយឈ្មោះ [redacted] ឡេះ ក្នុងអំឡុងឆ្នាំ១៩៨៧ នៅខេត្តក្រចេះ ក្រោយពីរៀបការរហូតមកដល់សព្វថ្ងៃនេះពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ។ មុនពេលរៀបការ និងក្នុងពេលរៀបការខ្ញុំដឹងថាប្តីរបស់ខ្ញុំពោះម៉ាយ និងមិនដឹងថាមានកូនឬអត់ទេ ។ បីឆ្នាំក្រោយមកនៅពេលដែលខ្ញុំទៅរកស៊ីជាមួយឈ្មោះ យ៉ុម នៅភូមិពុកឫស្សី-ខេត្តកណ្តាល ទើបដឹងថាប្តីរបស់ខ្ញុំមានកូន ៤ នាក់រួចទៅហើយ ។ នៅឆ្នាំ១៩៩២ខ្ញុំនិងប្តីមករស់នៅខេត្តរតនគិរីដោយប្រកបមុខរបរកាប់សត្វគោ សត្វក្របី ឲ្យគេ និងឈ្នៀតពេលលក់ត្រីបន្ថែមទៀត ។ នៅឆ្នាំ១៩៩៦ ឬ១៩៩៧ ប្តីរបស់ខ្ញុំក៏បានហៅកូនចំនួន២នាក់ឈ្មោះ [redacted] ដាត និងឈ្មោះ [redacted] ហ្សាគី ឲ្យមករកស៊ីកាប់សត្វគោ ក្របី ជាមួយគ្នា តែទទួលប្រាក់ដាច់ដោយឡែកពីគ្នា បន្ទាប់កូនឈ្មោះ [redacted] រ៉ានី ក៏មករកស៊ីដូចគ្នានៅខេត្តនេះដែរ ដោយឡែកឈ្មោះ [redacted] ទូរី មិនបានមករកស៊ីនៅ ខេត្តរតនគិរីនេះទេ ។ ក្នុងពេលកូនទាំងបីនាក់មករស់នៅនិងប្រកបមុខរបរនៅខេត្តរតនគិរីសុទ្ធតែមានប្រពន្ធរួចហើយលើកលែងតែឈ្មោះ [redacted] រ៉ានី និងបានចែកដីឲ្យកូនឈ្មោះ [redacted] ហ្សាគី ទទួលបានចំណែកដីទំហំ១៧ម៉ែត្រគុណ២២ម៉ែត្រ តួបក្នុងផ្សាបានលុង១កន្លែង និងឈ្មោះ [redacted] ដាត ទទួលបានចំណែកដីទំហំ១៧ម៉ែត្រគុណ២២ម៉ែត្រ និងដីនៅភូមិថ្មីទទួលបាន១៥ម៉ែត្រគុណ២៥ម៉ែត្រ រួចហើយ ។ ឈ្មោះ [redacted] រ៉ានី បានរៀបការឲ្យនិងបានចងដៃជាមាសទម្ងន់៥ជី ។ ខ្ញុំមករស់នៅជាមួយប្តីមានកូនថែមទៀតគឺ ឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ២៨ឆ្នាំ (កូនដើមរបស់ខ្ញុំ) ឈ្មោះ [redacted] រ៉ូស្រាក់ ភេទប្រុស អាយុ២៦ឆ្នាំ ឈ្មោះ [redacted] ឧសភា ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ជារី ភេទស្រី អាយុ១២ឆ្នាំ ដែលកូនៗទាំងអស់នេះកំពុងរស់នៅក្នុងបន្ទុករបស់ខ្ញុំ ។ ចំពោះបញ្ហាទ្រព្យសម្បត្តិចាប់ពីពេលរៀបអាពាហ៍ពិពាហ៍មកដល់ថ្ងៃនេះមានតែដីល័នៅហានមួយកន្លែងដែលសង់ផ្ទះសំរាប់រស់នៅ និងសង់ផ្ទះជាបន្ទប់ៗបានចំនួន២៣បន្ទប់ ។ ដីល័នៅហាននេះមានទំហំប្រហែល ២៦ម៉ែត្រគុណ៦៨ម៉ែត្រ នៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។ ចំពោះបំណុលវិញគឺ ជំពាក់ប្រាក់ធនាគារចំនួន២ ០០០ដុល្លារ ជំពាក់ប្រាក់លោកជំទាវ [redacted] ម៉ែន សារុន ចំនួន៨០០ដុល្លារ ជំពាក់ប្រាក់ចៃស្រីនៅសហរដ្ឋអាមេរិកចំនួន៥០០ដុល្លារ ជំពាក់ប្រាក់ឈ្មោះ ឡែន នៅភ្នំពេញចំនួន៥០០ដុល្លារ ជំពាក់ប្រាក់ថ្លៃដីចំនួន៦២៥០ដុល្លារ ជំពាក់ប្រាក់តាំតុយទាវហោះ ចំនួន៣០០ដុល្លារ ជំពាក់ប្រាក់យាយវែងចំនួន១៧០ដុល្លារ ជំពាក់ប្រាក់ឈ្មោះ [redacted] មាត ចំនួន២៥០ដុល្លារ



Scanned with CamScanner

ជំពាក់ប្រាក់ឈ្មោះ ម៉ាន (សុវណ្ណា)ចំនួន១៤៥ដុល្លារ ជំពាក់ប្រាក់ប្រពន្ធតាសេនចំនួន៥០ដុល្លារ ជំពាក់ប្រាក់ក្នុងវិហាចំនួន១០០ដុល្លារ ជំពាក់ប្រាក់ឈ្មោះ [redacted] ម៉ាក់ចំនួន១០០ដុល្លារ ជំពាក់ប្រាក់ឈ្មោះ [redacted] អ៊ិន ចំនួន១៧០០ដុល្លារ ចំណាយព្យាបាលជម្ងឺអស់ប្រាក់ចំនួន១៧០៥៧ដុល្លារ ចំណាយធ្វើបុណ្យសពអស់ប្រាក់ចំនួន១៤៦០ដុល្លារ

បានឃើញលោក [redacted] ជាមេធាវីនិងជាតំណាងដោយអាណត្តិឲ្យសហដើមចោទទាំង៤រូប បានដាក់លិខិតចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៣ មកចៅក្រម ដោយស្នើសុំឲ្យចៅក្រម អញ្ជើញមន្ត្រីជំនាញនៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ខេត្តរតនគិរី ចូលរួមសក្សា និងវាយតម្លៃលើដីទំនាស់ដោយជាក់ស្តែង ។

បានឃើញកំណត់ហេតុចុះពិនិត្យកស្តុតាងដីលំនៅឋាន ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ របស់តុលាការខេត្តរតនគិរី ។

បានឃើញគំនូសបង្ហាញទីតាំងដី ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ របស់មន្ត្រីជំនាញនៃមន្ទីររៀបចំដែន ដីនគរូបនីយកម្ម និងសំណង់ ខេត្តរតនគិរី ដីទំហំសរុប ១៨០៣ម² មានសំណង់ផ្ទះទំហំ១៣៨ម² មានសំណង់សង់ជាបន្ទប់ៗ សរុបចំនួន៦៣បន្ទប់ ។

២/ចំណុចវិវាទក្នុងរឿងក្តី

សហដើមចោទទាមទារឲ្យតុលាការបង្គាប់មកចុងចម្លើយឲ្យធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សពឈ្មោះ [redacted] ឡេះ ក្នុងនោះមានដីទំហំ៦៦ម៉ែត្រគុណ៦៨ម៉ែត្រ នៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មានសំណង់ផ្ទះ មានសំណង់ផ្ទះបន្ទប់ចំនួន៦៣បន្ទប់ ។

ចុងចម្លើយមិនព្រមបែងចែកមត៌កនោះទេ ។

ដោយគូភាគីមិនឯកភាពគ្នា ទោះបីតុលាការបានធ្វើការព្យាយាមដើម្បីផ្សះផ្សាសម្រុះសម្រួល ឲ្យសះជាទីងគ្នាវិញ តែគូភាគីនៅតែមិនព្រមសះជាទីងគ្នាឡើយ គប្បីតុលាការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងឈានទៅកំណត់កាលបរិច្ឆេទការទាញហេតុផលដោយផ្ទាល់មាត់ ។

**តុលាការខេត្តរតនគិរី**

**សំអាងហេតុ**

១/ពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ របស់សហដើមចោទឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ាទី និងឈ្មោះ [redacted] ទូរី ធ្វើឡើងតាមកំណត់ច្បាប់ត្រង់មាត្រា៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី ។

២/ឈ្មោះ [redacted] ឡេះ មានកូនគឺឈ្មោះ [redacted] ដាត ភេទប្រុស អាយុ៤៩ឆ្នាំ ឈ្មោះ [redacted] ហ្សាគី ភេទប្រុស អាយុ៤១ឆ្នាំ ឈ្មោះ [redacted] រ៉ាទី ភេទប្រុស អាយុ៣៣ឆ្នាំ ឈ្មោះ [redacted] ទូរី ភេទប្រុស អាយុ២៥ឆ្នាំ ឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted] រ៉ូស្រាក់ ភេទប្រុស អាយុ២៦ឆ្នាំ ឈ្មោះ [redacted] ឧសកា ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ជារី ភេទស្រី អាយុ១២ឆ្នាំ ហើយឈ្មោះ [redacted] ឡេះ បានទទួលមរណភាពនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ។

៣/តាមសេចក្តីថ្លែងការណ៍របស់សហដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់ ធ្វើការបែងចែកទ្រព្យសម្បត្តិរបស់សពឈ្មោះ [redacted] ឡេះ ដែលមានដីទំហំ៦៦ម៉ែត្រគុណ៦៨ម៉ែត្រ មានសំណង់ផ្ទះ មានសំណង់ផ្ទះល្វែងសង់ជាបន្ទប់ៗសរុបចំនួន៦៣បន្ទប់ នៅភូមិ៧មករា សង្កាត់ឡាបានសៀក



Scanned with CamScanner

ក្រុងបានលុង ខេត្តរតនគិរី មកឲ្យសហដើមចោទឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ានី និងឈ្មោះ [redacted] ទូរី ដែលត្រូវជាកូនរបស់សព ។

៤/តាមសេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ បានលើកឡើងនូវឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី បានទទួលចំណែកដីរួចរាល់អស់ហើយ កាលពីឪពុកនៅរស់ តែចុងចម្លើយមិនបានបង្ហាញភស្តុតាងអ្វីឡើយ ។

៥/តាមសេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយបានលើកឡើងថា ក្នុងអំឡុងពេលដែលប្តីមានជម្ងឺ បានចំណាយប្រាក់ព្យាបាលជម្ងឺអស់ច្រើន ក្រោយមកគាត់ទទួលមរណភាព បានចំណាយប្រាក់អស់ជាច្រើនក្នុងពេលធ្វើពិធីបុណ្យសព នៅមានការជំពាក់បំណុលគេយ៉ាងច្រើន តែចុងចម្លើយមិនបានបង្ហាញភស្តុតាងអ្វីឡើយ ទើបសម្រេចមិនធ្វើការបែងចែកទ្រព្យសម្បត្តិនេះ ម្យ៉ាងទៀតនៅមានការចិញ្ចឹមកូនចំនួន៤នាក់ទៀតគឺឈ្មោះ [redacted] សេងហុង ឈ្មោះ [redacted] រ៉ូស្រាក់ ឈ្មោះ [redacted] ឧសភា និងឈ្មោះ ដែលកំពុងរស់នៅក្នុងបន្ទុក ជាមូលហេតុមិនស្របច្បាប់ ។

៦/ប្តីឈ្មោះ [redacted] ឡេះ និងប្រពន្ធឈ្មោះ [redacted] ម៉ាស់ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ។ ប្តីប្រពន្ធ ពិតជាមានកូនចំនួន៨នាក់ឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ានី ឈ្មោះ [redacted] ទូរី ឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted] រ៉ូស្រាក់ ភេទប្រុស អាយុ២៦ឆ្នាំ ឈ្មោះ [redacted] ឧសភា ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ជារី ភេទស្រី អាយុ១២ឆ្នាំ ។

៧/ការអះអាងរបស់ចុងចម្លើយថាបានចែកដីឲ្យកូនឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី ព្រមទាំងបានលើកឡើងអំពីការជំពាក់បំណុល ការចំណាយប្រាក់ក្នុងការព្យាបាលជម្ងឺនិងការចំណាយក្នុងការធ្វើបុណ្យសព គឺពុំបានដាក់ភស្តុតាងជូនតុលាការពិនិត្យទេ ដូច្នេះការអះអាងរបស់ចុងចម្លើយមិនអាចយកជាការបានឡើយ ។

៨/ទ្រព្យសម្បត្តិរបស់សពឈ្មោះ [redacted] ឡេះ មានដីទំហំ១៨០៣,៨ម៤ មានសំណង់ផ្ទះទំហំ១៣៨ម៤ មានសំណង់ផ្ទះល្វែងសង់ជាបន្ទប់ៗសរុបចំនួន២៣បន្ទប់ នៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី តាមគំនូសបង្ហាញទីតាំងដីទំនាស់ ដែលមានកូន៨នាក់គឺ ឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ានី ឈ្មោះ [redacted] ទូរី ឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted] រ៉ូស្រាក់ ភេទប្រុស អាយុ២៦ឆ្នាំ ឈ្មោះ [redacted] ឧសភា ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ជារី ភេទស្រី អាយុ១២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] ម៉ាស់ ទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិនេះក្នុងលំដាប់ទី១ មានចំណែកស្មើៗគ្នា ។

៩/សហដើមចោទឈ្មោះ [redacted] ដាត ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ានី និងឈ្មោះ [redacted] ទូរី មានសំណូមពរទាមទារចំណែកពាក់កណ្តាល នៃដីទំហំ១៨០៣,៨ម៤ មានសំណង់ផ្ទះទំហំ១៣៨ម៤ មានសំណង់ផ្ទះល្វែងសង់ជាបន្ទប់ៗសរុបចំនួន២៣បន្ទប់ រីឯចុងចម្លើយឈ្មោះ [redacted] ម៉ាស មានសំណូមពរមិនចែកមត៌ក គប្បីតុលាការបដិសេធចោលដោយផ្អែកនឹងច្បាប់ ។

## សេចក្តីវិនិច្ឆ័យបញ្ជាប់

១/ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ របស់សហដើមចោទឈ្មោះ ឡេះ ដាត ឈ្មោះ [redacted] ហ្សាគី ឈ្មោះ [redacted] រ៉ានី និងឈ្មោះ [redacted] ទូរី ធ្វើឡើងតាមកំណត់ច្បាប់ត្រង់មាត្រា៧៥ ១២៧០ក្រមនីតិវិធីរដ្ឋប្បវេណី

២/ប្រគល់មត៌ក(ដីទំហំ១៨០៣ម៤ មានសំណង់ផ្ទះទំហំ១៣៨ម៤មានសំណង់ផ្ទះល្វែងសង់ជាបន្ទប់ៗសរុបចំនួន២៣បន្ទប់) នៅភូមិ៧មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ឲ្យទៅឈ្មោះ ទ ម៉ោស់ ចំនួនពាក់

៤៣៨



Scanned with CamScanner

កណ្តាលនៃមត៌ក នៅសល់មត៌កពាក់កណ្តាលទៀតប្រគល់ឲ្យសន្តតិជនឈ្មោះ [redacted] ដាត ភេទប្រុស អាយុ៤៩ឆ្នាំ ឈ្មោះ [redacted] ហ្សាគី ភេទប្រុស អាយុ៤១ឆ្នាំ ឈ្មោះ [redacted] រ៉ៃនី ភេទប្រុស អាយុ៣៣ឆ្នាំ ឈ្មោះ [redacted] ទូរី ភេទប្រុស អាយុ២៥ឆ្នាំ ឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted] រ៉ូស្រាក់ ភេទប្រុស អាយុ២៦ឆ្នាំ ឈ្មោះ [redacted] ឧសភា ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ជារី ភេទស្រី អាយុ១២ឆ្នាំ ព្រមទាំងប្រពន្ធឈ្មោះ [redacted] រ៉ម៉ាស មានចំណែកស្មើៗគ្នា គិតចាប់ពីសាលក្រមចូលជាស្ថាពរ តាមមាត្រា ១២៦៧ ១២៦៨ ក្រមរដ្ឋប្បវេណី។

៣/ប្រដាប់ក្តីជាបន្ទុកលើដើមចោទ

សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៦ ខែ១២ ឆ្នាំ២០១២និងថ្ងៃទី២១.០២.២០១៣ និងប្រកាសជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តរតនគិរី នូវចំពោះមុខដើមចោទនិងចុងចម្លើយ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ធ្វើនៅរតនគិរី ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

ហត្ថលេខាឆ [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ធ្វើនៅរតនគិរី ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

រតនគិរី ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣

**ចៅក្រមជំនុំជម្រះ**

[redacted]